




















សកម្មភាព ៖ **តើមេរោគមួយណាគឺជាខ្ញុំ?**

ចិត្តចលភាព ៖ បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

ភាសាខ្មែរ ៖ ការស្តាប់ (ស្តាប់គេនិយាយ និងមានសម្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ)។

គោលបំណង ៖

(ចិត្តចលភាព) ៖ ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

(ភាសាខ្មែរ) ៖ ប្រាប់បានខ្លះៗពីដំណើររឿងតាមរយៈរូបភាពដែលបានបង្ហាញ។
ប្រាប់បានពីសកម្មភាពតាមសំណាក់កាលដោយអនុវត្តតាមការណែនាំ។

កម្រិតសិក្សា ៖ ទាប មធ្យម ខ្ពស់

រយៈពេល ៖ ៣០ នាទី

សេចក្តីណែនាំ ៖

១.ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែងតើមេរោគមួយណាគឺជាខ្ញុំ? ជាមួយកូនៗទាំងអស់គ្នា។

២. សួរក្មេងៗ៖ តើមេរោគមានរូបរាងដូចម្តេច? ពណ៌របស់មេរោគ មានភ្នែកប៉ុន្មាន រូបរាងរបស់មេរោគជើងមេរោគ...ជាដើម។

៣. បង្ហាញរូបភាពមេរោគហើយនិយាយពិពណ៌នាមេរោគឱ្យក្មេងៗបានចងចាំ និង ជាគំរូសម្រាប់ក្មេងៗធ្វើការពិពណ៌នាដែរ
ហើយសូមកូនៗពិនិត្យមើលមេរោគដោយប្រុងប្រយ័ត្នហើយព្យាយាមចងចាំលំអិតអំពីពួកវា។

៤. បិតក្រដាសកាតមេរោគដែលបានត្រៀមទុក នៅលើក្តារខៀនឱ្យបានស្អាត និងការមួយឈុតទៀត ទុកសម្រាប់ចែកឱ្យក្មេងៗនពេលដែលក្មេងៗឡើងមកពិពណ៌នាពីមេរោគម្នាក់មួយសន្លឹកៗ។

៥. បន្ទាប់មក គ្រូជ្រើសរើសរូបភាពមួយដោយចៃដន្យហើយនិយាយពិពណ៌នាមេរោគនោះ និងឱ្យក្មេងណាម្នាក់ឡើងលើក្តារខៀន ទៅចង្អុលមេរោគដែលបានបិទនៅលើក្តារខៀននោះ។
(ការធ្វើនេះដើម្បីជួយពង្រឹងការចងចាំក្មេងៗអំពីមេរោគ)។

៦. ហៅក្មេងម្នាក់ឱ្យឡើងពិពណ៌នាមុនគេ ដោយផ្តល់នូវរូបភាពមួយសន្លឹកដោយមិនអនុញ្ញាតឱ្យកុមារផ្សេងទៀតមើលឃើញនោះទេ។

៧. ចាប់ផ្តើមឱ្យក្មេងម្នាក់នោះ ពិពណ៌នាតែម្តង និងគ្រូត្រូវហៅក្មេងៗដែលនៅមុខមកចង្អុលរូបមេរោគឱ្យត្រូវនឹងការពិពណ៌នាផងដែរ។

៨. ប្រសិនបើក្មេងនោះ ចង្អុលត្រូវ នោះក្មេងទាំងពីរ នឹងត្រូវបានទៅកន្លែងវិញ ប៉ុន្តែប្រសិនបើក្មេងនោះ ចង្អុលខុសនោះ ក្មេងដែលពិពណ៌នានោះ ត្រូវពិពណ៌នាម្តងទៀត
ឬជ្រើសរើសក្មេងណាម្នាក់ផ្សេងទៀតមកចង្អុលម្តង រហូតដល់ចង្អុលត្រូវ ទើបអាចផ្លាស់ប្តូរអ្នកពិពណ៌នាបាន។

៩. ធ្វើបែបនេះរហូតដល់អស់កាតដែលបានត្រៀមទុកនោះ ជាការស្រេច។

១០. ចំពោះគូរណាដែលបានស្វែងរកឃើញហើយនោះ គឺពួកគេត្រូវឈរនៅតាមលំដាប់លំដោយជាមួយដៃគូររបស់ពួកគេ។

១១. ចាប់ផ្តើមពីថ្ងៃអាទិត្យ ចន្ទ អង្គារ....។ ពួកគេអាចមើលទៅកាន់ក្តារខៀន ដើម្បីដឹងទៅតាមលំដាប់លំដោយ ឱ្យបានត្រឹមត្រូវជាការស្រេច។